# មេរៀនដែលទទួលបានពីការផ្សព្វផ្សាយបច្ចេកទេស ប.ខ.ស នៅកម្ពុជា

ក្នុងចំណាត់ជើងមួយ "ពីសំណាបមួយដើមទៅស្រូវរាប់រយដើម" នៃបច្ចេកទេស ប.វ.ស (ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ) របស់ EDN 2001 (របាយការណ៍នៃការអភិវឌ្ឍន៍របស់អេកូ ឆ្នាំ ២០០១) ដែលអត្ថបទដំបូងរបស់អេកូ បានផ្តោតទៅលើរបៀបនៃការផលិតស្រូវ ដែលជាចំណុចសំខាន់របស់ ប.វ.ស រួមមាន:



- ស្ទូងសំណាបខ្ចីអាយុពី ៨-១៥ ថ្ងៃ ដែលមានស្លឹក២
- ស្ទូងសំណាប ១ដើម ក្នុង ១គុម្ព
- ស្ទូងសំណាបឃ្លាតពីគ្នាដោយទុកចន្លោះគុម្ព ២៥សង់ទីម៉ែត្រ x ២៥សង់ ទីម៉ែត្រ
- រក្សាលក្ខខណ្ឌដីក្នុងស្រែឲ្យសើមជានិច្ច ប៉ុន្តែមិនត្រូវឲ្យមានទឹកដក់ច្រើននៅក្នុងស្រែ
- ប្រើជីធម្មជាតិដូចជា ជីកំប៉ុស្ត, ជីលាមកសត្វ និងជីបៃតងមាសផ្សេងទៀត។

ចាប់ពីឆ្នាំ ២០០១ មកការរួមបញ្ចូលគ្នានៃក្រុមកសិករ, អង្គការក្រៅរដ្ឋាភិបាល និងក្រសួងនានានៅតំបន់អាស៊ីបានគិតគូ និងជួយជំរុញដល់ប្រព័ន្ធនៃការផលិតស្រូវ។ ឥឡូវ ៨ឆ្នាំបានកន្លងផុតទៅរបាយការណ៍របស់ country-wide សំរាប់អាស៊ីអាគ្នេយ៍ និងតំបន់ជុំវិញគឺកំពុងបង្ហាញពីកំរិតនៃការផ្លាស់ប្តូរជាច្រើនចំពោះការទទួលយកនូវប្រព័ន្ធនេះពីកសិករ។

## ការពិនិត្យមើលមួយត្រួសពី ប.វ.ស. ក្នុងតំបន់

សំរាប់ការពិនិត្យមើលពីស្ថានការណ៍ របស់ ប.វ.ស នៅអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ មានវេបសាយមួយបានដាក់ឈ្មោះឲ្យគេហទំព័រគេថា SRI (http://ciifad.cornell.edu/sri/index.html) ដោយមានការសហការពី Association Tefy Saina, Antanarivo, Madagascar និង the Cornell International Institute for Food, Agriculture and Development (CIIFAD) ផ្តល់ជូនរបាយការណ៍របស់ប្រទេសនានាស្តីពីសកម្មភាព ប.វ.ស ជុំវិញពិភពលោក។ ជាឧទាហរណ៍ វេបសាយសរសេរថា ចន្លោះឆ្នាំ ២០០៧ ដល់ ២០០៨ ការធ្វើ កសិកម្មតាម ប.វ.ស ក្នុងខេត្តស៊ីឈាន ប្រទេសចិន បានកើនពី ១១៦,៦៦៧ ហិចតា ដល់ ២០៤,០០០ ហិចតា (http://ciifad.cornell.edu/sri/countries/china/index.html)។

មានព័ត៌មានស្តីពីដីប្រមាណជា ១១,០០០ ហិចតាស្ថិតក្នុងការធ្វើកសិកម្មតាម ប.វ.ស នៅតំបន់មួយចំនួន របស់ប្រទេសឥណ្ឌូនេស៊ី (http://ciifad.cornell.edu/sri/countries/indonesia/index.html) ប៉ុន្តែគេហទំព័រ ផ្តល់តិចតួចនូវទិន្នន័យនៃការផលិត ឆ្នាំ ២០០៨ តាម ប.វ.ស សំរាប់ប្រទេស ថៃ, ម៉ាឡេស៊ី, ហ្វីលីពីន និងប្រទេសឡាវ ។ បន្ថែមពីលើនេះកសិករ ៥០,០០០ នាក់ក្នុងរដ្ឋកាចាន់ និងសាន របស់ប្រទេសភូមា ត្រូវបានគេរាយការណ៍ថា កំពុងប្រើប្រាស់នូវវិធីមួយចំនួនរបស់ ប.វ.ស លាយបញ្ចូលគ្នា (http://ciifad.cornell.edu/sri/countries/myanmar/index.html) រីឯកសិករ ៩៥,០០០ នាក់នៅខេត្តហាតាយ ប្រទេស វៀតណាម ក៏ប្រើវិធីស្រដៀងគ្នានេះដែរ (http://ciifad.cornell.edu/sri/countries/vietnam/index.html) ។

ក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាគួរឲ្យកត់សំគាល់បំផុត ក្នុងក្រុមនៃប្រទេស ដែលអនុវត្ត ប.វ.ស។ យោងលើរបាយការណ៍របស់ប្រទេស កត់នៅលើគេហទំព័រ (http://ciifad.cornell.edu/sri/countries/cambodia/index.html) ដោយការប្រើទិន្នន័យរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទបានឲ្យដឹងថា ចុងឆ្នាំ ២០០៨ មាន ១០៤,៣៥០ គ្រួសារក្នុង ៤,២០០ ភូមិលើផ្ទៃដី ៥៨,២៩០ ហិចតា (២.៣ភាគរយនៃចំនួនដីសរុបរបស់ប្រទេស) កំពុងអនុវត្តបច្ចេកទេស ប.វ.ស។

**ការផ្តោតលើប្រទេសកម្ពុជា**

របាយការណ៍ស្តីពីការរីកចំរើន ប.វ.ស នៅប្រទេសកម្ពុជាចោទជាសំណួរមួយចំនួនដូចជា តើអ្វីទៅអាចជំរុញឲ្យកសិករកម្ពុជាដើម្បីចាប់យក ប.វ.ស? តើលទ្ធភាពប្រើប្រាស់នូវធនធានធម្មជាតិដូចជាដីស្រែចំការ និងធារាសាស្ត្រ (ឬក៏មិនមានលទ្ធភាពទទួល) មានឥទ្ធិពលលើចំលើយនេះដូចម្តេច? តើក្រសួងនានា, អង្គការក្រៅរដ្ឋាភិបាល និងកសិករកម្ពុជាផ្តល់ជាគំរូមួយចំនួនដល់តំបន់ ដែលមិនអនុវត្ត ប.វ.ស ដើម្បីឲ្យធ្វើតាមឬទេ? ហើយបទពិសោធន៍ដូចគ្នានេះដែរ ត្រូវបានគេអនុវត្តទៅលើការបញ្ចូលគំនិតថ្មីដទៃទៀត ក្នុងកសិកម្មនិរន្តភាព?

ជាមួយការទាក់ទងនឹងចំនួននៃការសាកល្បង ប.វ.ស ដ៏ខ្ពស់ ដែលត្រូវបានគេរាយការណ៍ នៅក្នុងប្រទេសកម្ពុជា។ នៅខែមេសា ឆ្នាំ ២០០៩ អ្នកនិពន្ធរបស់ EAN បានរៀបចំកិច្ចសម្ភាសន៍ជាមួយ លោក យឹម សុខសុភាស់ ដែលគាត់ជាមន្ត្រីកម្មវិធីរបស់អង្គការ CEDAC (Centre d’Etude et de Developpement Agricole Cambodgien) នៅភ្នំពេញ។

សុខសុភាស់ បានធ្វើការជាមួយអង្គការ សេដាក តាំងពីឆ្នាំ ២០០៣ មានតួនាទីជាអ្នកធ្វើការតាមមូលដ្ឋានក្នុងការផ្សព្វផ្សាយ ប.វ.ស និងកម្មវិធីផ្សេងៗទៀត ដែលមានការទាក់ទងនឹងការផ្សព្វផ្សាយកសិកម្ម និងអភិវឌ្ឍន៍ជនបទ។ កិច្ចសម្ភាសន៍ជាមួយ លោក យឹម សុខសុភាស់មានដូចតទៅ:

**តើអង្គការសេដាកផ្តើមចាប់អារម្មណ៍ពី ប.រ.ស តាមរបៀបណា?**

មុនដំបូង ប្រធានអង្គការសេដាក បណ្ឌិត យ៉ង់ សាំងកុមារ អានពីការចាប់ផ្តើម ប.រ.ស នៅលើចំណាងជើង មួយរបស់ទស្សនាវដ្តី LEISA ក្នុងឆ្នាំ ១៩៩៩ ដោយមានការចាប់អារម្មណ៍ខ្លាំង គាត់ក៏បានចាប់ផ្តើមពិសោធន៍ នូវការផលិតស្រូវមួយដែលមិនធ្លាប់មានពីមុនដោយធ្វើនៅកៀកនឹងដីស្រែរបស់គាត់។

**តើ ប.រ.ស. ត្រូវបានអនុវត្តតាមដោយវិធីណាសំរាប់កសិករកម្ពុជា?**

ការចាប់ផ្តើមជាមួយការអនុវត្តមុនគេបំផុតរបស់ បណ្ឌិត យ៉ង់ សាំងកុមារ និងក្រុមកសិករដំបូងគេរបស់ សេដាក បានប្រើប្រាស់ការស្រាវជ្រាវពីសកម្មភាពដែលចូលរួមដើម្បីប្រមែប្រមូល និងធ្វើវិភាគព័ត៌មានដែលទាក់ទងនឹងការប្រែប្រួលតាមតំបន់ និងការអនុវត្តន៍តាម ប.រ.ស។ ជាដំបូង បណ្ឌិត យ៉ង់ សាំងកុមារ បានសហការជាមួយ កសិករ ម៉ី សោម ដែលគាត់មានដីស្រែចំនួន ០.៥ ហិចតា ស្ថិតនៅភូមិត្រពាំងរាំង ស្រុកអង្គស្នួល ខេត្តកណ្តាល។ បន្ទាប់មកក្នុងឆ្នាំ ២០០០ សេដាក បានចាប់ផ្តើមការសហការជាផ្លូវការជាមួយកសិករ ២៨នាក់ នៅខេត្តចំនួន ៤ (កណ្តាល, ព្រៃវែង, កំពង់ធំ និងកំពង់ចាម)។

**តើអាត្រានៃការអនុវត្តតាម ប.រ.ស របស់កសិករកម្ពុជាបានកើនឡើងលឿនដូចម៉េចនៅក្នុងឆ្នាំបន្តទៅមុខទៀត?**

ត្រឹមឆ្នាំ ២០០៥ កសិករ ៤០,០០០ គ្រួសារក្នុង ២,៥០០ ភូមិ ក្នុងស្រុកចំនួន ២០ បានអនុវត្តតាម ឬក៏យកលំនាំតាមនូវវិធីមួយចំនួនរបស់ ប.រ.ស។ ហើយត្រឹមឆ្នាំ ២០០៧ កសិករ ៨០,០០០ គ្រួសារក្នុងខេត្តចំនួន ២៤ បានអនុវត្តតាម ឬក៏យកលំនាំតាមនូវបច្ចេកទេស ប.រ.ស ។

**តើលទ្ធផលរបស់អង្គការ ដែលទាក់ទងនឹងការអនុវត្តតាម ប.រ.ស ទាំងអស់ត្រូវបានគេចងក្រងយ៉ាងដូចម្តេច?**

សេដាក រួមសហការជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីរកមនុស្សឱ្យកាន់ការជាទីភ្នាក់ងារលេខាធិការ ប.រ.ស ដែលទទួលភារកិច្ចជាអ្នកប្រមូលទិន្នន័យ ប.រ.ស ពីគ្រប់អង្គការក្រៅរដ្ឋាភិបាល និងក្រសួងកសិកម្មខេត្ត។ របាយការណ៍ ដែលបានមកថ្មីបំផុតគឺអាចរកបាន នៅលើគេហទំព័ររបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ (www.maff .gov.kh) និងសុវត្ថិភាពស្បៀងរបស់ប្រជាជនកម្ពុជា (www.foodsecurity.gov.kh) ។

**តើការរួមសហការនៃអង្គការក្រៅរដ្ឋាភិបាលដទៃទៀត និងអង្គការស្រាវជ្រាវមួយចំនួនត្រូវបានធ្វើឱ្យ ជាប់ទាក់ទិនក្នុងការវាយតម្លៃដំបូងរបស់ ប.រ.ស ?**

អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត គឺមិនត្រូវបានគេធ្វើឱ្យជាប់ទាក់ទិនទៅនឹងការវាយតម្លៃ និងការផ្សព្វផ្សាយ ប.រ.ស ទេរហូតដល់ជិតឆ្នាំ ២០០៥។ នៅខែកញ្ញា ឆ្នាំដដែលនោះ សេដាក និងអង្គការក្រៅ

រដ្ឋាភិបាលចំនួន ៣០ ដែលធ្វើការលើកសិកម្មធម្មជាតិ និងការអភិវឌ្ឍន៍ជនបទ ផ្ដើមបង្កើតជាបណ្ដាញនៃការអភិវឌ្ឍន៍កសិកម្មធម្មជាតិក្នុងប្រទេសកម្ពុជា (NEDC) ។ នៅពេលក្រោយមក មន្ទីរកសិកម្មខេត្តក៏បានចូលរួមផងដែរ។

**តើមធ្យោបាយមួយចំនួនជាមូលដ្ឋានក្នុងការពង្រីកបន្តដែលទាក់ទងនឹងការងារ ប.វ.ស មុនដំបូងគឺជាអ្វី?**



សេដាកបានប្រើមធ្យោបាយក្នុងការពង្រីកបន្តពីកសិករមួយទៅកសិករមួយទៀតដើម្បីបង្រៀនអ្នកធ្វើស្រែ តាម បច្ចេកទេស ប.វ.ស ដូចជានៅថ្ងៃទិវាស្ទូងស្រូវ ប.វ.ស កសិករអាចមានទាំងការពិនិត្យដោយផ្ទាល់ និងឱកាស ដើម្បីចូលរួមក្នុងការបង្កើតឲ្យមាន ការដាំតាមប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ។ ដោយសារការចុះទៅអនុវត្តផ្ទាល់ ដូច្នេះកសិករអាចយល់ច្បាស់ពីសារៈសំខាន់នៃគោលការណ៍ ប.វ.ស ដូចជា ដំណាក់កាលដ៏សមរម្យដើម្បីស្ទូង កូនសំណាបឲ្យល្អ និងសារៈសំខាន់នៃការស្ទូងតាមខ្សែបន្ទាត់។ សេដាកក៏បាន រៀបចំវគ្គបណ្ដុះបណ្ដាលកសិករ ដើម្បីឲ្យអនុវត្តន៍នូវការជ្រើសរើសពូជល្អ និងធ្វើយ៉ាងណាដើម្បីបង្កើនដីជាតិ ដីនៅស្រែទាប់លើ។

សំខាន់ជាងនេះទៀតគឺនៅទិវាប្រមូលផលស្រូវ ប.វ.ស កសិករបានចូលរួមប្រមូលផលស្រូវ ដោយច្រូតស្រូវ ប.វ.ស លើផ្ទៃដីស្រែ ២ម៉ែត្រ x ២ម៉ែត្រ និងស្រែតាមទំលាប់លើផ្ទៃដីដូចគ្នា ដើម្បីពិនិត្យដើមស្រូវដែលច្រូតចេញពីកន្លែងទទួលទិន្នផលល្អ មធ្យម និងអន់ក្នុងស្រែទាំងពីរប្រភេទ។ កសិកររួមគ្នាប្រៀបធៀបលើចំនួនដើមបែកក្នុង ១គុម្ព និងចំនួនគួរស្រូវក្នុង ១គុម្ព ព្រមទាំងទិន្នផលសរុបនៃស្រូវដែលបានផលិត។ នៅទីបញ្ចប់ភាពខុសគ្នាក្នុងចំណោមបច្ចេកទេសទាំងពីរបានធ្វើឲ្យកសិករជាច្រើនមានការជឿជាក់ប្រាកដ ហើយជួយឲ្យពួកគាត់គិតពីភាពសមស្របរបស់ ប.វ.ស ។

លើសពីនេះទៀត នៅកំឡុងពេលស្រូវកំពុងលូតលាស់ចន្លោះពេលស្ទូង និងច្រូតកាត់ កសិករដែលមានការចាប់អារម្មណ៍ អាចចូលរួមក្នុងទស្សនៈកិច្ចសិក្សា ដើម្បីមើលពីការផលិតស្រូវទាំង ២ របៀបលើបច្ចេកទេស ប.វ.ស និងស្រែធ្វើតាមទំលាប់ ដើម្បីប្រៀបធៀបភាពខុសគ្នាពីដំណាក់កាលលូតលាស់ និងការគ្រប់គ្រងដំណាំស្រូវ ។

ការប្រមូលទិន្នន័យក៏ជាការងារមួយដ៏សំខាន់ក្នុងការជំរុញ ប.វ.ស ។ កសិករដែលចូលរួមសហការអនុវត្តន៍ផលិតស្រូវតាម ប.វ.ស និងតាមទំលាប់គឺត្រូវបានគេបង្រៀនពីវិធីប្រមូលទុកនូវទិន្នន័យ ដែលសំខាន់ៗតាមរដូវកាលលូតលាស់ស្រូវមានដូចជា:

- បច្ចេកទេសផលិតស្រូវ (តាមប.វ.ស ឬក៏តាមទំលាប់)
- ធនធានធម្មជាតិ ដែលមាន (បរិមាណនៃដីកំប៉ុស្តដែលប្រើ ។ល។)
- ការសង្កេតពីការដុះលូតលាស់របស់ដំណាំស្រូវ
- បញ្ហាជួបប្រទះ និងវិធីដោះស្រាយ
- ទិន្នផល។

បន្ទាប់ពីប្រមូលផលកាត់ អង្គការសេដាក បានបង្កើតឱ្យមានសិក្ខាសាលាឡើង ដែលមានការចូលរួមពីកសិករដែលមានបទពិសោធន៍ធ្វើស្រូវតាម ប.វ.ស កសិករខាងក្រៅដែលមិនបានសហការ និងអាជ្ញាធរមូលដ្ឋាន (ឧ. មេភូមិ, សមាជិកក្រុមប្រឹក្សាឃុំ) ក្នុងគោលបំណងដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នា ទៅវិញទៅមកពីការផលិតស្រូវតាម ប.វ.ស ។ នៅកំឡុងពេលសិក្ខាសាលាស្តីពីការប្រមូលផលស្រូវនោះ សមាជិកអង្គសិក្ខាសាលាបាន:

- ចែករំលែកបទពិសោធន៍ ដែលទាក់ទងបច្ចេកទេស ប.វ.ស ជាពិសេសបទពិសោធន៍ល្អៗរបស់កសិករ ដែលបានអនុវត្តន៍
- បង្ហាញនូវបញ្ហាដែលបានកើតមាន
- បង្ហាញពីវិធីក្នុងការដោះស្រាយបញ្ហា
- ដាក់ផែនការសំរាប់អនុវត្តន៍នៅរដូវក្រោយ។

កសិករ ប.វ.ស ដែលសំខាន់បំពេញមុខងារមិនគ្រាន់តែជាគំរូ ប៉ុន្តែជាធនធានមនុស្សសំរាប់បង្ហាត់បង្រៀនកសិករផ្សេងទៀតក្នុងសមាគមកសិករតាមភូមិរបស់ពួកគេ។

នៅពេលបានគិតពិចារណាគ្រប់ជ្រុងជ្រោយឃើញថា វិធីសាស្ត្រផ្សព្វផ្សាយពីកសិករទៅកសិករ ជាពិសេស ការបង្រៀនអ្នកផលិតស្រូវឱ្យក្លាយជាអ្នកបង្រៀនបន្ត និងសកម្មភាពមួយចំនួន ដែលទាក់ទងទៅនឹងការស្ទង់ និងការ ប្រមូលផលកាត់ គឺមានសារៈសំខាន់បំផុតទាក់ទងនឹងការជំរុញបច្ចេកទេស ប.វ.ស ។

## សំភារៈបង្ហាត់បង្រៀនអ្វីដែលត្រូវបានអភិវឌ្ឍន៍ដើម្បីជាជំនួយដល់ការផ្សព្វផ្សាយ ប.វ.ស ?

នៅពេលចាប់ផ្តើម យើងមានប្រព័ន្ធផ្សាយព័ត៌មានដូចជា កូនសៀវភៅ ប.វ.ស, ខិត្តប័ណ្ណ និងរូបភាពធំៗគឺ ត្រូវបានរៀបចំសំរាប់គោលដៅក្នុងការបង្រៀន ព្រមទាំងវីដេអូ ប.វ.ស បានផលិត ពីរបីឆ្នាំមុន។

ពេលថ្មីៗនេះ អុកស្វាមអាមេរិក (Oxfam-America) បានធ្វើការសហការជាមួយ សេដាក ដើម្បីផលិតវីដេអូសំរាប់អប់រំមាន ចំណងជើងថា " *ប្រព័ន្ធប្រពលវប្បកម្មស្រូវ* " *Do You Speak SRI?* ដ៏មានប្រជាប្រិយ (បានចេញផ្សាយក្នុងឆ្នាំ ២០០៨) ។ ការផលិតវីដេអូថ្មី គឺបានផ្តល់នូវសារៈសំខាន់ជាទីបំផុតដល់ការបង្រៀន និងការផ្សព្វផ្សាយពី ប.វ.ស ជាពិសេសក្នុងចំណោមកសិករដែលមិនចេះអក្សរ។ ទោះបីយ៉ាងណាគ្រឿងផ្សាយព័ត៌មាន ដែលត្រូវបានប្រើទូលំទូលាយជាងគេដោយអង្គការ សេដាក ដើម្បីផ្សព្វផ្សាយ ប.វ.ស គឺទស្សនាវដ្តីកសិករដែលចេញផ្សាយរាល់ខែ។

វីដេអូ ប.វ.ស គឺមានប្រយោជន៏យ៉ាងពិសេសដើម្បីបង្ហាញក្នុងកំឡុងពេលដើមរដូវវស្សា ពេលដែលកសិករកំពុងចាប់ផ្តើមរៀបចំធ្វើស្រែ។ ទោះបីជាយ៉ាងណាក៏ដោយ ទស្សនាវដ្តីកសិករដែលចេញផ្សាយរាល់ខែក៏ផ្តល់នូវព័ត៌មានទៀងទាត់ពីអនុសាសន៏ចំពោះការធ្វើកសិកម្ម ជាពិសេស ប.វ.ស រហូតដល់ពេញមួយឆ្នាំដែរ។

## កសិករកម្ពុជាដែលអនុវត្តន៍តាម ប.វ.ស មានភាពខុសប្លែកគ្នាពីទំរង់បច្ចេកទេស ប.វ.ស ដទៃទៀតដែលបានផ្សព្វផ្សាយជុំវិញពិភពលោកយ៉ាងដូចម្តេច?



តាមការអនុវត្តន៏ជាក់ស្តែង ប.វ.ស នៅកម្ពុជាមានភាពប្រហាក់ប្រហែលគ្នាតែម្តង ក្នុងការអនុវត្តន៏ដោយប្រើបច្ចេកទេសសំខាន់ៗ ចំនួន ១២។ ប៉ុន្តែបច្ចេកទេសមួយចំនួនអាចត្រូវបានគេផ្លាស់ប្តូរ អាស្រ័យលើលក្ខខណ្ឌនៃតំបន់។ ឧទាហរណ៏ ដីស្រែដែលខ្វះដីជាតិអាចតម្រូវឲ្យស្ទូងចន្លោះគុម្ពជិតជាងដីស្រែ ដែលមានដីជាតិ។ ក្នុងដីស្រែ ប.វ.ស ដែលមានដីជាតិច្រើន ពេលខ្លះសំណាបគឺត្រូវបានស្ទូងឃ្លាតឆ្ងាយពីគ្នា ៤០~៥០សង់ទីម៉ែត្រ។ ទោះយ៉ាងណាចំងាយនៃការស្ទូងសំណាបដែលសមស្របគឺពី ២០~៣០ សង់ទីម៉ែទ្រ។

ជាទូទៅទោះជា ប.វ.ស ផ្តោតលើការស្ទូងសំណាបតែមួយដើមក៏កសិកកម្ពុជានៅតែស្ទូងពី ២~៣ដើម ក្នុង ១គុម្ព ក្នុងដីស្រែ ដែលទទួលរងការជន់លិចជាហេតុបង្កឲ្យមានបញ្ហាច្រើនជាមួយសត្វល្អិតកាត់ស្លឹកស្រូវ។ *ទាំងនេះគឺជាការសង្ខេបនូវបច្ចេកទេសសំខាន់ៗចំនួន ១២ ដែលបានផ្សព្វផ្សាយដោយ អង្គការសេដាក*

- *ធ្វើដីឲ្យបានរាបស្មើ និងមានប្រព័ន្ធសំរាប់បញ្ចេញទឹក*
- *ប្រើជីធម្មជាតិ ជាពិសេសជីកំប៉ុស្តដើម្បីឲ្យដីផុសល្អ*
- *ដកស្មៅ និងបំផុសដីឲ្យបាន ២~៤ដង ដើម្បីឲ្យខ្យល់ចេញចូលល្អ*

- *ស្ទូងឲ្យរង្វើលពីគ្នា ដោយទុកចន្លោះពី ២.៥-៤តឹក*
- *ដកថ្នមៗ យកតែសំណាបណាថ្លោសៗ រួចយកទៅស្ទូងភ្លាមៗ*
- *ស្ទូងជាជួរដោយចំងាយពីគុម្ពមួយទៅគុម្ពមួយស្មើៗគ្នា*
- *ជៀសវាងកុំឲ្យមានទឹកដក់ច្រើនទៅក្នុងស្រែ ពេលស្រូវកំពុងលូតលាស់*
- *ស្ទូងចាប់ស្តើង យកល្អស្ទូងតែ១ដើមក្នុង១គុម្ព*
- *ស្ទូងសំណាបអាយុខ្ចី យកល្អអាយុត្រូវតិចជាង ១៥ថ្ងៃ*
- *ធ្វើថ្នាលសំណាបគោក ហើយសាបស្តើង ដើម្បីឲ្យសំណាបថ្លោសល្អ*
- *ស្ទូងថ្នមៗ រាក់ៗ និងកុំបត់ឫសដូចផ្លែសន្ទូច*
- *ប្រើពូជសុទ្ធល្អ និងរើសតែគ្រាប់ពេញល្អសំរាប់យកទៅសាប។*

**តើកសិករកម្ពុជាអនុវត្តតាមបច្ចេកទេសទាំង ១២នេះ?**

ប្រសិនបើកសិករអនុវត្តបានគ្រប់ចំណុចទាំង ១២ នោះទិន្នផលនឹងទទួលបានច្រើន។ ប៉ុន្តែសូម្បីពេលដែលពួក គាត់មិនអាចធ្វើបានគ្រប់ចំនុចទាំងអស់ក៏ពួកគាត់នៅតែអាចកែសំរួលវាទៅតាមលក្ខខណ្ឌនៃអាកាសធាតុដែរ។ ឧទាហរណ៍ ការអនុវត្តន៏ខ្លះប្រហែលជាចាំបាច់ត្រូវការកែតម្រូវទឹកន្លែងណា ដែលដីស្រែទទួលទឹកច្រើនពេក។ ដោយហេតុនេះសំណាប ដែលត្រូវយកទៅស្ទូង ត្រូវបន្ថែមចំនួនដើម្បីការពារការបំផ្លាញពីសត្វល្អិតចង្រៃ។

ហើយក្នុងការឆ្លើយតបចំពោះលក្ខខណ្ឌសំណើមតិច ថ្នាលសំណាបប្រហែលជាត្រូវសាប នៅពេលវេលាខុសគ្នាបន្តិចបន្តួច។ ការសាបចាំបាច់ត្រូវបានពន្យា ព្រោះតែសំណើមមិនគ្រប់គ្រាន់ និងបរិមាណរបស់គ្រាប់ពូជដែល បានសាបក្រោយគេ វាអាចដុះនៅពេលចុងបញ្ចប់មានសំណើមគ្រប់គ្រាន់ក្នុងថ្នាល។ សូម្បីតែស្ថិតក្រោម លក្ខខណ្ឌធម្មតាក៏ដោយ ថ្នាលសំណាបភាគច្រើនរួមផ្សំនឹងការផ្លាស់ប្តូរពេលវេលាសាប អាចធ្វើឲ្យកសិករអនុវត្តការសាបបានដោយគ្មានការព្រួយបារម្ភពីកូនសំណាបមានអាយុចាស់ពេក។

ជាធម្មតា កសិករភាគច្រើនអនុវត្តបច្ចេកទេស ប.វ.ស យ៉ាងតិចបំផុតចំនួន ៥ ចំនុច។ ប៉ុន្តែអ្នកដែលអនុវត្តពី ៨ ទៅ១០ ចំនុចតែងតែទទួលបាននូវលទ្ធផលល្អជាង។

*ជួនកាលរឿងមួយបានបង្កើនកង្វល់ខ្លះ ទាក់ទងនឹងទិន្នន័យ ប.វ.ស និងការអនុវត្តន៏។ នៅពេលមានទិន្នន័យស្ថិតិ គឺវាមានប្រយោជន៏ក្នុងការវាស់វែងនូវការផ្សព្វផ្សាយរបស់ប.វ.សនៅប្រទេសកម្ពុជា, វាក៏មាន*

*ប្រយោជន៍ដែរក្នុងការយល់ច្បាស់ពីលក្ខណៈវិនិច្ឆ័យពិតប្រាកដមួយដើម្បីប្រើប្រាស់នូវវិធីហ្វឹកហ្វឺនឲ្យកសិករមានសមត្ថភាពធ្វើជាអ្នកអនុវត្តន៍តាម។ ឧទាហរណ៍ ដោយពិចារណាពីបច្ចេកទេសទាំង ១២ចំនុច របស់ ប.វ.ស តើគេត្រូវតែប្រតិបត្តិអោយបានត្រឹមត្រូវប៉ុន្មានចំនុចនៃបច្ចេកទេសមុនពេលកសិករម្នាក់អាចត្រូវបានគេចាត់ទុកថាជាអ្នកសាកល្បង?*

## តើនេះជាការទទួលយកបច្ចេកទេសប.វ.ស ក្នុងចំណោមកសិករកម្ពុជាដើម្បីបន្តរការដាំដុះឬក៏ជាការចាប់ផ្តើម?

ការទទួលយក ប.វ.ស បានកំពុងកើនឡើងយ៉ាងខ្លាំង ហើយការអនុវត្តន៍បច្ចេកទេសសំខាន់ៗដែលពួកគាត់យកទៅអនុវត្តន៍គឺអាចកាត់បន្ថយបរិមាណពូជ ការប្រើប្រាស់សំណាបខ្ចី ការស្ទូងស្រូវមួយដើមក្នុង មួយគុម្ពស្ទូងរង្វើល ការប្រើជីកំប៉ុស្ត និងការកាត់បន្ថយការប្រើប្រាស់ជីគីមី។ បន្ថែមទៀតនោះដោយយោងតាមរបាយការណ៍ របស់ក្រសួងកសិកម្មឆ្នាំ ២០០៨ បានបង្ហាញថា ជាទូទៅទិន្នផលស្រូវអនុវត្តតាម ប.វ.ស ភាគច្រើនទទួលបានផល ២ដង ច្រើនជាងការដាំដុះធម្មតា។ ដោយយោងទៅតាមរបាយការណ៍ (សកម្មភាព ប.វ.ស នៅប្រទេសកម្ពុជា) របាយការណ៏នេះបានដាក់បញ្ចូលទៅក្នុងគេហទំព័រប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ប.វ.ស *http://ciifad.cornell.edu/sri/countries/cambodia/index.html* ចំណែកទិន្នន័យឆ្នាំ ២០០៨ ពីលេខាធិការដ្ឋាន ប.វ.ស បានបង្ហាញថា ជាមធ្យម (បច្ចេកទេស ប.វ.ស គឺបានផ្តល់ទិន្នផលស្រូវ ៣.៥៤ តោន ក្នុងមួយហិកតាទិន្នផលនេះច្រើនជាង ១តោន បើប្រៀបធៀបទិន្នផលតាមទំលាប់ ហើយ ៤០ភាគរយ ច្រើនជាងទិន្នផលជាមធ្យមថ្នាក់ជាតិ ចំនួន ២.៥៤តោន ក្នុងមួយហិកតា ទិន្និផលនេះមានការកើនឡើង ០.៥តោនក្នុងមួយហិកតា បើប្រៀបធៀបជាមួយឆ្នាំ ២០០៧ អាចប្រៀបធៀបជាមួយកសិករ ដែលបានអនុវត្ត ប.វ.ស មិនគ្រប់តាមគោលការណ៏បច្ចេកទេសផងដែរ ។

## តើ ប.វ.ស នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេទទួលយកតាមតំបន់ឬក៏ទទួលយកពេញប្រទេសតែម្តង ?

បច្ចេកទេស ប.វ.ស បានកំពុងអនុវត្តនតាមគ្រប់តំបន់ ប៉ុន្តែការអនុវត្តន៏នេះគឺអាស្រ័យតាមលក្ខខណ្ឌតំបន់នីមួយៗ។ ជាឧទាហរណ៏ នៅក្នុងតំបន់ដែលគ្មានប្រព័ន្ធស្រោចស្រពសំរាប់ដំណាំស្រូវ ការអនុវត្តន៏បច្ចេកទេស ប.វ.ស បានកំពុងទទួលយកនៅក្នុងតំបន់ដែលធ្វើស្រូវ។ ដែលបច្ចេកទេសបានកំពុងអនុវត្ត មានដូចតទៅ :

- ការកំណត់ចំនួនដើមស្ទូងស្រូវពី ២~៣ដើមក្នុងមួយគុម្ព (បើប្រៀបធៀបជាមួយចំនួនដើមដែលស្ទូងតាមទំលាប់ ) ជាមួយគំលាតពីចន្លោះគុម្ពមួយទៅគុម្ពមួយ

~ នៅពេលខ្លះនៅតំបន់ខ្ពស់រាប ការដកសំណាបស្ងួត (១-៣ ដើម ក្នុង១គុម្ព) ហាក់ដូចជាទទួលបានទិន្នផលស្មើ ឬតិចជាងការដាំ ឬព្រោះគ្រាប់ផ្ទាល់

**តើជីសរីរាង្គដូចជា (កំប៉ុស្ត ) ជានិច្ចជាកាលត្រូវបានគេប្រើញឹកញាប់ឬ ?**

កសិករជាច្រើនបានប្រើប្រាស់ជីកំប៉ុស្ត ទោះបីជាការប្រើប្រាស់ជីធម្មជាតិទាំងនេះ មានលាយជីគីមីខ្លះក៏ដោយ។ តែទោះជាយ៉ាងណាការធ្វើស្រូវសរីរាង្គគឺប្រើតែជីកំប៉ុស្តតែមួយមុខប៉ុណ្ណោះ។ (យោងតាមរបាយការណ៍ការប្រើប្រាស់ជីកំប៉ុស្តសំរាប់ការអនុវត្តន៍បច្ចេកទេស ប.វ.ស នៅក្នុងប្រទេសកម្ពុជា អង្គការ សេដាក បានកត់សំគាល់ថាទិន្នផលស្រូវដែលប្រើប្រាស់កំប៉ុស្តគឺទទួលបានទិន្និផលចាប់ ពី ១០ ទៅ ១៥តោន ក្នុងមួយហិកតា។ ប៉ុន្តែការអនុវត្តន៍របស់កសិករជាក់ស្តែងទទួលបានទិន្នផលស្រូវទាបជាងនេះ ទោះបីកសិករបានប្រើប្រាស់កំប៉ុស្តតែមួយមុខ ឬបានប្រើប្រាស់គ្រប់ចំនួនក៏ដោយ។ លោក *Tom Post* ជាប្រធានអង្គការ *(CRWRC)* បានបង្ហាញថា ដីនៅក្នុងប្រទេសកម្ពុជាសំរាប់ផលិតកម្មស្រូវនៅតែមិនសូវមានជីជាតិតែបើមានការប្រើប្រាស់ជីកំប៉ុស្ត តិចតួចក៏ធ្វើឲ្យមានការខុសប្លែកច្រើននៅក្នុងការធ្វើឲ្យដីមានជីជាតិ និងអាចបង្កើនទិន្នផលស្រូវបានផងដែរ។ ប៉ុន្តែទិន្នផលស្រូវ ដែលបានពីការកែប្រែគុណភាពដីនៅតែជាបញ្ហាដែរ។ មានកសិករនៅក្នុងសហគមន៍ពន្លឺ ខេត្តតាកែវ ភាគខាងត្បូង ទីក្រុងភ្នំពេញជាកន្លែងដែលអង្គការគ្រប់ជ្រុងជ្រោយធ្វើការ បានកត់សំគាល់ថាប្រសិនបើការធ្វើស្រែនៅឆ្ងាយពីផ្ទះការប្រើប្រាស់ជីកំប៉ុស្តនឹងបានតិចតួច លទ្ធផលនេះដោយយោងទៅតាមផលលំបាក ដែលកសិករពិបាកក្នុងការដឹកជញ្ជូនជីទៅដាក់ក្នុងស្រែ។ ស្រដៀងគ្នានេះដែរ អង្គការដៃគូគ្រប់ជ្រុងជ្រោយ បង្ហាញថា ដំណាំជីស្រស់ដូចជា សណ្តែកអង្រៃ សណ្តែកអង្គុយ ដែលបានដាំដុះនៅក្នុងវាលស្រែ ហើយភ្ជួរកប់ទៅក្នុងដី នៅតែមិនទាន់បានអនុវត្តទូលំទូលាយនៅឡើយដោយសារតែខ្លាច គោស៊ីនៅវាលស្រែ។ គេអាចដាំដុះជីស្រស់ទាំងនេះបាន នៅកន្លែងជិតផ្ទះបានព្រោះគេអាចមើលថែទាំដំណាំ ឲ្យជៀសផុតពីគោស៊ីបានជាងការដាំដំណាំនៅឆ្ងាយពីផ្ទះ។

**តើ ប.វ.ស បានកំពុងអនុវត្តន៍ពាសពេញនៅប្រទេសកម្ពុជា? បើប្រៀបធៀបជាមួយកសិករនៅប្រទេសជិតខាង?**

នៅដំណាក់កាលដំបូងអង្គការនៅប្រទេសកម្ពុជាមានពីរ ឬបី ប៉ុណ្ណោះ ដែលបានយកចិត្តទុកដាក់ទៅលើបច្ចេកទេស ប.វ.ស។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលបច្ចេកទេស ប.វ.ស បានធ្វើឲ្យស្រូវមានទិន្នផលគួរឲ្យកត់សំគាល់របស់ក្រសួងកសិកម្ម ក៏បានធ្វើការគាំទ្របច្ចេកទេសនេះផងដែរ។ ជាក់ស្តែង ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទនៃប្រទេសកម្ពុជា បានសរសេរនិក្ខេបបទពី

បច្ចេកទេស ប.វ.ស ដែលនិក្ខេបបទនេះដើរតួយ៉ាងសំខាន់ក្នុងការគាំទ្របច្ចេកទេសពាសពេញប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ បច្ចេកទេសសំខាន់ៗ ចំបងទាក់ទងទៅនឹងការសាយភាយ ប.វ.ស នៅក្នុងប្រទេសកម្ពុជា បានបង្ហាញនូវលទ្ធផលល្អក្រោយពីការអនុវត្តន៏បច្ចេកទេស ប.វ.ស ពីកសិករ ដែលជារើយៗគេព្យាយាមអនុវត្តន៏បច្ចេកទេស ប.វ.ស ទាំងនេះ។

## តើកំលាំងពលកម្មជាកត្តាមួយដែលចាំបាច់ក្នុងការអនុវត្តន៍ ប.វ.ស ឬមិនចាំបាច់ ?

ជាដំបូងត្រូវមានការព្យាយាមច្រើនដើម្បីអនុវត្តបច្ចេកទេស ប.វ.ស ដូចជា ដំបូងយើងត្រូវរៀបចំធ្វើថ្នាលសំណាបឲ្យរាបស្មើ ជ្រើសរើសគ្រាប់ស្រូវពេញល្អ ដើម្បឲ្យបានសំណាបថ្លោសល្អ និងក្នុងរជាជួរសំរាប់ស្ទូងជាដើម។ ប៉ុន្តែចំពោះកសិករ ដែលគាត់ធ្លាប់ធ្វើការអនុវត្តន៏ គឺនៅតែមានលក្ខណៈងាយស្រួលក្នុងការអនុវត្តន៏ គឺមិនត្រូវការជំនាញច្បាស់លាស់នោះទេ។ តំរូវការមួយវិញទៀតនោះការធ្វើស្មៅ នៅក្នុងស្រែសំរាប់បច្ចេកទេស ប.វ.ស ទោះជាយ៉ាងណាក៏ដោយមានការកែច្នៃពិសេសសំរាប់ធ្វើស្មៅ នៅតាមចន្លោះជួរ ដែលមានការស្ទូងជាជួរដែលនាំឲ្យមានការលំបាកតិចតួច។ ជាទូទៅកសិករទទួលស្គាល់ថា ការធ្វើស្មៅមានប្រយោជន៏ជាច្រើនទាក់ទងទៅនឹងការជំរុញឲ្យដីមានខ្យល់ចេញចូលបានល្អនិងធ្វើឲ្យដំណាំស្រូវលូតលាស់ល្អ។

## ការទទួលយក ប.វ.ស សំរាប់ប្រជាជនកម្ពុជា បានទូលំទូលាយប៉ុន្តែមិនដូចគ្នាឬ ?

តាមរបាយការណ៏របស់លោក David Strong អ្នកធ្វើការងារអភិវឌ្ឍន៏ក្នុងសមាគម (CAMA) គឺសមាគម (ផ្តល់សេចក្តីមេត្តា និងប្រោសប្រណី) ដែលធ្វើការនៅភាគពាយព្យ (ខាងជើងភាគខាងលិច ដែលបានចូលរួម ការងារជាច្រើនទាក់ទងទៅនឹងការលើកកំពស់បច្ចេកទេស ប.វ.ស ក្នុងកំឡុង ឆ្នាំ២០០៤ យល់ឃើញថា បច្ចេកទេស ប.វ.ស ទោះបីជាមានការអនុវត្តច្រើននៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏លោក David សង្កេត ឃើញថាការទទួលយកទៅអនុវត្តន៏នូវមានកំរិត និងអាស្រ័យតាមតំបន់ របស់ពួកគេដដែល។ លោក David ក៏ បានធ្វើការកត់សំគាល់ទៀតថា មានកត្តាពីរសំខាន់ដែលទាក់ទងទៅនឹងការអនុវត្តបច្ចេកទេស ប.វ.ស នៅខេត្តបាត់ដំបងនៅមានកំរិតទាបគឺ : កត្តាទី១ បច្ចេកទេស ប.វ.ស ទំនងជាមានការងាយស្រួលសំរាប់កសិករមានផ្ទៃដីតូចនៅភាគពាយព្យនៃប្រទេសកម្ពុជា។ ហើយបើសិនយើងគិតទៅលើផ្ទៃដីស្រូវដែលមានទំហំធំ ហើយក្នុងរាស់ដោយត្រាក់ទ័រនោះគឺមានការពិបាកជាង។ ទន្ទឹមនេះផងដែរ ដោយសារកសិករនៅភាគពាយព្យនៃប្រទេសកម្ពុជាជាច្រើនពឹងលើធម្មជាតិទាំងស្រុង ហេតុនេះហើយទើបការអនុវត្តន៏បច្ចេកទេស ប.វ.ស នៅតែមានឧបសគ្គច្រើនទាក់ទងនឹងការបញ្ចេញបញ្ចូលទឹកនៅក្នុងដំណាក់កាលភ្ជួររាស់។ ជាឧទាហរណ៏ នៅ

ក្នុងកំឡុងពេលដើមឆ្នាំ មិនមានភ្លៀងគ្រប់គ្រាន់សំរាប់សំណាប ដែលនៅខ្ចីសំរាប់អនុវត្តបច្ចេកទេស ប.វ.ស ធ្វើឲ្យសំណាបងាយងាប់ ដោយសារទឹកតិចតួច ហើយវាអាចធ្វើទៅរួចទាល់តែបូមទឹកពីតំបន់ដែលមានប្រភពទឹក នៅជិត។

ក្នុងកំឡុងពេលដែលសមាគមផ្តល់សេចក្តីមេត្តា និងព្រោសប្រណី (CAMA) កំពុងបន្តសកម្មភាពយ៉ាងសកម្មក្នុងការលើកកំពស់ការអនុវត្តន៏បច្ចេកទេស ប.វ.ស នៅខេត្តបាត់ដំបង កត្តាចំបងគឺកត្តាភូមិសាស្ត្រ។ ដូចនេះលោក David Strong បានសន្និដ្ឋានថា ការអនុវត្តន៏បច្ចេកទេស ប.វ.ស គឺនៅតែមិនអាចទៅរួចក្នុងតំបន់ភាគពាយព្យប្រទេស។

## ការប្រមូលមេរៀន ប.វ.ស ពីកសិករ

តើវាគឺជាមេរៀនដែលបានប្រមូលចេញពីអ្នក ដែលបានអនុវត្តបច្ចេកទេស ប.វ.ស នៅក្នុងប្រទេសកម្ពុជា? មានយោបល់ខ្លះបានសង្កេតឃើញថា មានកត្តាមួយចំនួនទាក់ទងនឹងបច្ចេកទេសប.វ.ស ដែលបច្ចេកទេស គឺជាបច្ចេកទេស ដែលអាស្រ័យច្រើន ទៅនឹងការស្ទូងស្រូវនៅតាមតំបន់ដែលគេរស់នៅ។ ដូចដែលលោកបណ្ឌិត យ៉ង់ សាំងកុមារ ប្រធានអង្គការសេដាកបានថ្លែងថា ( ស្រូវគឺជាដំណាំដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា ហើយមានប្រជាជនកម្ពុជាប្រហែល ៦០ ទៅ ៦៥ ភាគរយ (ក្រៅពី ១៤លាននាក់ ) គឺជាអ្នកធ្វើស្រូវ ដែលកត្តានេះមានសក្តានុពលខ្លាំងទៅលើបច្ចេកទេស ប.វ.ស ជាពិសេសបច្ចេកទេសនេះ មានប្រយោជន៏ច្រើនទៅលើកសិករតូចតាច ដែលជាកត្តាចំបងក្នុងការជួយជំរុញសេដ្ឋកិច្ចប្រទេសឲ្យទៅមុខលឿន។ អង្គការសេដាកជាអង្គការមួយដែល មានតួនាទីចំបងក្នុងការគាំទ្រនឹងលើកកំពស់បច្ចេកទេស ប.វ.ស ឲ្យមានការផ្សព្វផ្សាយកាន់តែខ្លាំងទៅលើផលិតកម្មដំណាំស្រូវនូវប្រទេសកម្ពុជាដែលជាសន្ទុះដ៏ប្រសើរទាក់ទៅនឹងការអនុវត្តន៏ជាមួយដៃគូផ្សេងៗជាក់ស្តែងនៅកំឡុងឆ្នាំ២០០៤ លេខាធិការដ្ឋាន ប.វ.ស ត្រូវបានគាំទ្រដោយស្ថាប័នរដ្ឋាភិបាលកម្ពុជាតែមួយគត់ និងអង្គកាជាច្រើនរួបរួមគ្នា។ បន្ថែមទៀតនោះវប្បធម៌នៃការអភិវឌ្ឍន៍ ដែលសមស្របសំរាប់បច្ចេកទេស ប.វ.ស នោះគឺការគាំទ្រឲ្យមានប្រសិទ្ធិភាពតាមរយៈកម្មវិធីការផ្សព្វផ្សាយពីកសិករមួយទៅកសិករមួយ ដែលជាផ្នែកមួយយ៉ាងសំខាន់ធ្វើឲ្យបច្ចេកទេសមានការរីកលូតលាស់ នៅក្នុងប្រទេសកម្ពុជា។ តែទោះបីជាយ៉ាងនេះក្តីការទទួលយកបច្ចេកទេស ប.វ.ស នៅក្នុងប្រទេសកម្ពុជាបានបង្ហាញយ៉ាងច្បាស់នូវការផ្សព្វផ្សាយយ៉ាងធំធេងហើយបានបង្ហាញផងដែរនូវការចាប់ផ្តើមគាំទ្រដែលកើតមានឡើងតិចជាងមួយទសវត្សរ៍ ក្នុងបច្ចេកទេស ប.វ.ស ហើយធ្វើឲ្យបច្ចេកទេសនេះ ហាក់ដូចជា មានទំនុកចិត្តអំពីតួនាទីក្នុងប្រព័ន្ធផលិតកម្មដំណាំស្រូវឲ្យបានផលច្រើន។

*(របាយការណ៍លើកដំបូងរបស់ ECHO ស្តីពីបច្ចេកទេស ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ប.វ.ស ) ដែលបាន បោះពុម្ពផ្សាយនៅក្នុង EDN Issue 70 ប្រចាំខែ (មករា ឆ្នាំ ២០០១ )។ និងមានរបាយការណ៍ ពីឆ្នាំបន្ទាប់ ដែលមានទំនាក់ទំនង និងបានដាក់បញ្ចូលនូវបច្ចេកទេស ប.វ.ស ( ប.វ.ស ត្រូវបានផ្តល់នូវការកែតម្រូវជាច្រើនពីបណ្តេញ) EDN Issue 71 ប្រចាំខែ (មេសា ឆ្នាំ ២០០១ ) ដូចជា (របាយការណ៍ ប.វ.ស ) EDN Issue 72 ប្រចាំខែ (កក្កដា ២០០១) និង (ប.វ.សថ្មីៗ ) EDN Issue 77 ប្រចាំខែ (តុលា ២០០២)។*
*http://www.echotech.org/mambo/index.php?option=com_docman&task=cat_view&gid=13&dir=DESC&order=name&limit=10&limitstart=30*

*ថ្មីៗនេះមានការសរសេរនូវអត្ថបទជាច្រើនស្តីពី បច្ចេកទេស ប.វ.ស ដែលបានដាក់បញ្ចូលទៅទៅក្នុង EDN Issue ១០២ ប្រចាំខែ(មករា ២០០៩) (មានមតិជាច្រើនមកដល់ពេលនេះមិនទាន់គិតថាតើ ការអនុវត្តន៍ បច្ចេកទេស ប.វ.ស ទទួលបានផលច្រើនឬទេ? http://www.echotech.org/mambo/index.php?option=com_docman&task=cat_view&gid=13&Itemid=68.]*

**អំណរអំណាង**

- អង្គការសេដាក ស្តីពីគោលការណ៍បច្ចេកទេស ប.វ.ស ទាំង១២ចំណុច
- លោក David Strong, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០០៩
- គេហទំព័រ ប.វ.ស (ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ CIFAD ឆ្នាំ ២០០៨ សកលវិទ្យាល័យ Cornell )
- លោកបណ្ឌិត យ៉ង សាំងកុមារ ជាអ្នកផ្តល់នូវយុទ្ធសាស្ត្រសំខាន់ៗ ក្នុងផលិតកម្មដំណាំស្រូវ ក្នុងប្រទេសកម្ពុជា
- សេដាកជាអ្នកអភិវឌ្ឍន៍កសិកម្ម និងការប្រឹក្សាយោបល់ ខែមិថុនា ឆ្នាំ ២០០៨
- លោក យឹម សុខសុភាស់ ថ្ងៃទី ៥ខែ មេសា ឆ្នាំ ២០០៩
- ការផ្តល់សំភាសន៍ដោយ លោក យឹម សុខសុភាស់ក្នុង ថ្ងៃទី ២ ខែមេសា ឆ្នាំ២០០៩។


ដោយ: Rick Burnette

**នាយកការិយាល័យអេកូប្រចាំតំបន់អាស៊ី**

# អាស័យដ្ឋាន គេហទំព័រ និងធនធានផ្សេងៗទៀត

## ១. ការអនុវត្តន៍បច្ចេកទេស ប.វ.ស និងគេហទំព័រ សំភារ AV :

ទាក់ទងទៅនិងបច្ចេកទេស ប.វ.ស ដែលបានបញ្ជាក់កាលពីលើកមុន (គេហទំព័រ ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៏ធម្មជាតិ ប.វ.ស) (http://ciifad.cornell.edu/sri/index.html) ដោយមានការសហការពីសមាគម Association Tefy Saina និង CIIFAD ដែលផ្តោតទៅលើគុណសម្បត្តិនៃបច្ចេកទេស ប.វ.ស និងសំភារៈទាក់ទងទៅនិងការផ្សព្វផ្សាយផ្សេងៗទៀត។ ដោយឡែកការអនុវត្តបច្ចេកទេស ប.វ.ស និងសំភារៈ AV ដូចជាឯកសា PowerPoint និងវីដេអូនៅគេហទំព័រ (http://ciifad.cornell.edu/sri/manuals.html#videos) គឺបានបង្ហាញនៅក្នុងគេហទំព័រនេះ។ ភ្ជាប់ទៅនិងពត៌មានជាភាសាអង់គ្លេស បារាំង អេស្ប៉ាញ និងថែមទាំងផ្តល់ផងដែរនូវឯកសារជាភាសាផ្សេងៗទៀត ដែលស្ថិតនៅក្នុងប្រទេសសមាគមអាស៊ាន។

## ២. វិធីសាស្រ្ត ឬការណែនាំ

ការទាញយកឯកសារជាភាសា អង់គ្លេស មកប្រើប្រាស់ ដូចជា តើធ្វើដូចម្តេចដើម្បីដាំស្រូវឲ្យមានការលូតលាស់ល្អ និងផ្តល់ទិន្នផលខ្ពស់? វិធីសាស្រ្តនេះមាន ដូចជាការបង្រៀនដោយខ្លួនឯង និងវិធីផ្សេងទៀត។ ឯកសារដើមស្តីពីការអនុវត្តន៏ បច្ចេកទេស ប.វ.ស ត្រូវបានធ្វើឡើងដោយ មានការចូលរួមពី CIIFAD and Tefy Saina ។ ជាបន្ថែមទៀតទិន្នផលស្រូវ ប.វ.ស ច្រើនឬតិចគឺជាវិធីសាស្រ្តថ្មី នៃការ ប្រមូលផលស្រូវដែលបានផ្តល់នូវការបង្ហាញយ៉ាងច្បាស់លាស់ អំពីទិដ្ឋភាពទូទៅនៃបច្ចេកទេស ប.វ.ស ។ ក្នុងចំណោមការណែនាំ ជាភាសាផ្សេងៗនៅក្នុងសមាគមអាស៊ាន ដែលនៅក្នុងទំព័រនេះ គឺការបោះពុម្ព បច្ចេកទេស ប.វ.ស ជាភាសាថៃ (កាណែនាំ ប.វ.ស ជាភាសាថៃ)បានប្រមូលផ្តុំដោយផ្នែកផ្សព្វផ្សាយកសិកម្មនៅ ឯមជ្ឈមណ្ឌលស្តារឡើងវិញដោយឈៀងម៉ៃ ប្រទេសថៃ ឯកសារទាំងនោះក៏មានជាភាសា ឥណ្ឌូនេស៊ី ផងដែរប៉ុន្តែជាឯកសារ (PDF) ក្នុងនោះមានបង្ហាញនូវការណែនាំពី ប.វ.ស ដោយភាសាផ្សេងៗ នៅក្នុងសមាគមអាស៊ាន ភាគខាងត្បូង ផ្សេងទៀតនៃ ប្រទេស Nepali, Oriya, Telugu and Tamil ។

## ៣. បទបង្ហាញជាស្លាយ

ដើម្បីឲ្យមានការចាប់អារម្មណ៏ឲ្យកាន់តែខ្លាំងទៀតនោះ ឯកសារ ដែលទាក់ទង និងបច្ចេកទេស ប.វ.ស អាចស្រាវជ្រាវបានតាមរយៈ (ការអនុវត្តន៏បច្ចេកទេស ប.វ.ស និងសំភារៈ AV ) ដែលឯកសារនោះ

បានរួមបញ្ចូលនូវបទពិសោធន៍ការអនុវត្តន៍ ប.វ.ស នៅឆ្នាំ ២០០០ ដល់ ២០០៧ ដោយបណ្ឌិត យ៉ង់ សាំងកុមារ និងការកើនឡើងនូវការរក្សាទឹកទុកខណៈពេល ដែលទិន្នផលស្រូវមានការកើនឡើង ជាមួយ ប.វ.ស ដោយបណ្ឌិត Norman Uphoff ។ ឯកសារជាបទបង្ហាញផ្សេៗទៀត អំពី ប.វ.ស ពីសំណាបមួយដើមទៅស្រូវរាប់រយដើម ដោយ N.G Ranga of Agricultural University, Rajendranagar, Hyderabad, India, can be viewed online ។

## ៤. វិដេអូ

យើងអាចមើលឯកសារវិដេអូ ស្ដីពី ប.វ.ស បានតាមរយៈគេហទំព័រ ពេលខ្លះត្រូវការសំការៈខ្លះសំរាប់ជំនួយ ឬតាមរយៈគេហទំព័រ ដែលបានផ្ដល់ឲ្យទាំងនោះមានដូចជា :

- Systéme de Riziculture Intensive- Cambodge: Le riz du l'espoir, វិដេអូ ជាភាសា បារាំង Tefy Saina គេហទំព័រ (http://www.tefysaina.org/sri_video.htm)។

- SRI and SVA ដែលផ្ដល់នូវអត្ថបទជាភាសាអង់គ្លេស ជាមួយការអនុវត្ត ប.វ.ស ដែលបានគាំទ្រដោយ Sahabhagi Vikash Abhiyan (យុទ្ធនាការសំរាប់ការអភិវឌ្ឍន៍ដោយអង្គការ (នៅក្នុងភាគខាងជើងឈាងខាងលិចរដ្ឋអូរីសា នៅប្រទេសឥណ្ឌា )

- ឯកសារ វិដេអូ ជាភាសាកាណាដា (ផលិតដោយ Digital Green ) ដែលបានធ្វើការប្រៀបធៀបនូវបច្ចេកទេស ប.វ.ស ជាមួយនិងទិន្នផលស្រូវតាមទំលាប់នៅក្នុង Maraladoddi, Karnataka, India

- ឯកសារនោះមានវិធីសាស្ត្រផ្សេងមួយចំនួនទៀតក្នុងការដាំស្រូវដើម្បីឲ្យមានទំនុកចិត្តខ្ពស់ និង មានឯកសារជាវីដេអូ អំពី ប.វ.ស នៅក្នុងប្រទេសហ្វីលីពីន (មើចុះទៅក្រោមដើម្បីទទួកយកនូវឯកសារ ភាពយន្ត )

- ជាភាពយន្តឯកសាជាភាសា អង់គ្លេស ស្ដីពីការរស់នៅជាមួយនិងអាងទន្លេមេគង្គ នៅលើគេហទំព័រ YouTube ស្ដីពី ប.វ.ស និងការផលិតស្រូវនៅក្នុងប្រទេសថៃ ដែលឯកសារនោះផលិតដោយស្ថានីយ៍ទូរទស្សន៍ TVE អាស៊ី សំរាប់កម្មវិធី CGIAR ប្រកួតប្រជែងអាហារ និងទឹក។

## ព្រឹត្តិប័ត្រព័ត៌មាន ប.វ.ស ជាវិដេអូ របស់អង្គការ ADRA

ជាចុងក្រោយលោក Tom Post ជាមួយ CRWRC ថ្មីៗនេះបានផ្ដល់នូវអនុសាសន៍ជារួម ក្រោយពេលបានមើលការផលិតវីដេអូ ជាភាសាអង់គ្លេសរបស់អង្គការ ADRA ស្ដីពី ប.វ.ស នៅប្រទេសឥណ្ឌា ។

វីដេអូនេះ ប្រហែលចង់ផ្តោតទៅលើការអនុវត្តន៍បច្ចេកទេស http://www.youtube.com/watch?v= huif OQX6BkU ។

**អំណះអំណាង**

*ក្រុម ប.វ.ស (ការអនុវត្តន៍ ប.វ.ស និងផនធានសំភារៈ*AV*)* http://ciifad.cornell.edu/sri/manuals.html Copyright © 2006 Cornell University

*លោក* Tom Post *ថ្ងៃទី៥ ខែឧសភា ឆ្នាំ* 2009 ។

ដោយៈ Rick Burnette

នាយកការិយាល័យអេកូប្រចាំតំបន់អាស៊ី